**មហាសន្និបាត**

ការចែកចាយទូទៅ

ថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០០៣

អត្ថបទដើម: អង់គ្លេស

មហាសន្និបាត

សម័យប្រជុំលើកទី ៥៨

ចំណុចទី ៣៥៦ នៃរបៀបវារៈបណ្តោះអាសន្ន

បញ្ហាសិទ្ធិមនុស្ស: បញ្ហាសិទ្ធិមនុស្ស រួមទាំងការដោះដែលអាចមាន

ដើម្បីកែលំអការទទួលបានដោយប្រសិទ្ធភាពនូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន

# តួនាទី និងលទ្ធផល
# របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ
# ទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា
# ក្នុងការលើកតម្កើង និងការការពារសិទ្ធិមនុស្ស

## របាយការណ៍របស់លោកអគ្គលេខាធិការ

# សេចក្តីសង្ខេបខាងការប្រតិបត្តិ

របាយការណ៍នេះ មានពត៌មានស្តីពីតួនាទី និងលទ្ធផលទទួលបានរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ពីខែមករា ដល់ខែកក្កដា ឆ្នាំ ២០០៣ ក្នុងការជួយរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកតម្កើង និងការការពារសិទ្ធិមនុស្ស ។ របាយការណ៍នេះបានរៀបចំឡើងស្របតាមសេចក្តីសំរេចចិត្តរបស់មហាសន្និបាតលេខ A/RES/57/225 អនុម័តនៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០០២ ។

ការិយាល័យទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តធ្វើការយ៉ាងជិតស្និទ្ធ ជាមួយលោកតំណាងពិសេសរបស់លោកអគ្គលេខាធិការ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ក្នុងការបំពេញអាណត្តិរបស់លោក និងបានជួយសំរួលដល់បេសកកម្មលើកទី ៨ និងទី ៩ របស់លោកនៅកម្ពុជា ពីថ្ងៃទី ២៥ ខែកុម្ភៈ ដល់ថ្ងៃទី ៤ ខែមីនា និងពីថ្ងៃទី ៣០ ខែ មិថុនា ដល់ថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០០៣ ជាបន្តបន្ទាប់ ។

ដើម្បីជួយរដ្ឋាភិបាលក្នុងការបំពេញកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តឃ្លាំមើលស្ថានភាពសិទ្ធិមនុស្សជាទូទៅ ស៊ើបអង្កេតរបាយការណ៍ស្តីពីការរំលោភសិទ្ធិមនុស្សនានា និងរៀបចំឯកសារអំពីលំនាំនៃការរំលោភបែបនេះ ។ ការិយាល័យបានជូនពត៌មានអំពីសេចក្តីព្រួយបារម្ភរបស់ខ្លួនដល់អាជ្ញាធរខេត្ត និងជាតិ ដើម្បីសុំការអន្តរាគមន៍របស់ពួកគេ ។

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានពង្រឹងកម្មវិធីបោះឆ្នោតរបស់ខ្លួន ទាក់ទិនទៅនឹងការបោះឆ្នោតតំណាងរាស្ត្រ ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៣ ។ សកម្មភាពទាំងនេះ មានរួមបញ្ចូលការផ្តល់ជំនួយបច្ចេកទេស ដល់រដ្ឋាភិបាលក្នុងការរៀបចំសេចក្តីព្រាងច្បាប់ និងបទបញ្ជាស្តីពីការបោះឆ្នោត ការងារការពាររួមបញ្ចូលជាមួយការរំលោភសិទ្ធិមនុស្សក្នុងក្របខ័ណ្ឌនៃការបោះឆ្នោត ការផ្តល់ពត៌មានដល់រដ្ឋាភិបាល និងសហគមន៍អន្តរជាតិ ស្តីពីបរិយាកាសនយោបាយ និង បញ្ហាបោះឆ្នោត ព្រមទាំងធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ការរៀបចំ ការឃ្លាំមើលសិទ្ធិមនុស្សទាក់ទិននឹងការបោះឆ្នោត និងការឆ្លើយតបទៅការយកចិត្តទុកដាក់ខាងការការពាររបស់ពួកគេ ព្រមទាំងការជួយក្នុងការរៀបចំ របាយការណ៍ជាសាធារណៈចេញផ្សាយដោយលោកតំណាងពិសេស របាយការណ៍ ចុងក្រោយរបស់លោក គឺរបាយការណ៍មុនការបោះឆ្នោតត្រូវបានចេញផ្សាយនៅដើមខែកក្កដា ។

ដើម្បីជួយរដ្ឋាភិបាលក្នុងការអនុវត្តច្បាប់ភូមិបាលឆ្នាំ ២០០១ ឱ្យស្របទៅនឹងកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ប្រទេសកម្ពុជា ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានចាប់ប្រតិបត្តិការសិក្សាមួយដើម្បីរុករកផលប៉ះពាល់ចំការកសិកម្មដោយទ្រង់ទ្រាយធំ លើសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋរស់នៅក្នុង ឬជិតព្រំប្រទល់នៃចំការទាំងនេះ និងវិសាលភាពដែលចំការទាំងនេះបានរួមចំណែកដល់ការអភិវឌ្ឍន៍ សុខុមាលភាពខាងសេដ្ឋកិច្ច និងសង្គមរបស់ប្រជាពលរដ្ឋជាទូទៅ ។ ឈរលើលទ្ធផល ការសិក្សានេះនឹងផ្តល់អនុសាសន៍ដល់អាជ្ញាធរមានពាក់ព័ន្ធ និងទីភ្នាក់ងារអន្តរជាតិនានា ។

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បន្តរួមចំណែកក្នុងកិច្ចដំណើរការ និងកិច្ចខិតខំក្នុងការតាក់តែងច្បាប់ ដើម្បីជំរុញការកែទម្រង់តុលាការ តាមរយៈការផ្តល់អត្ថាធិប្បាយលើសេចក្តីព្រាងច្បាប់ ការសម្របសម្រួលការពិភាក្សា ក្នុងចំណោមភាគីដែលយកចិត្តទុកដាក់ លើបញ្ហានយោបាយច្បាប់ ការផ្តល់ដំបូន្មានស្តីពីបញ្ហាច្បាប់ ដោយផ្តោតជាពិសេសទៅលើកិច្ចដំណើរការ និងនីតិវិធីនៃយុត្តិធម៌ព្រហ្មទ័ណ្ឌ ក៏ដូចជាការឃ្លាំមើលការវិនិច្ឆ័យសេចក្តីនៅក្នុងប្រព័ន្ធតុលាការ ។ កាលពីពេលថ្មីៗនេះ ការិយាល័យបានផ្តួចផ្តើមឱ្យមានការសន្ទនា ជាមួយគណៈមេធាវី អាជ្ញាធរមានពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាល ស្តីពីជំនួយការច្បាប់ ការផ្តល់នូវអ្វីដែល បច្ចុប្បន្ននៅសេសសល់ នៅក្នុងគណៈមេធាវី និងអង្គការក្រៅរដ្ឋាភិបាល ដោយពុំបានទទួលថវិការពីរដ្ឋ ។ ការិយាល័យកំពុងប្រមូលទិន្នន័យ ដើម្បីធ្វើរបាយការណ៍មួយដើម្បីពណ៌នាសភាពការណ៍បច្ចុប្បន្ន ទាក់ទិនទៅនឹងការទទួលបានជំនួយផ្នែកច្បាប់ និងដើម្បី ធ្វើការវាយតម្លៃអំពីសេចក្តីត្រូវការរបស់ប្រទេសកម្ពុជា ក្នុងការធានាឱ្យមានការទទួលបាននូវ យុត្តិធម៌សំរាប់អ្នកក្រីក្រ ។

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា សកម្មក្នុងការអនុវត្តជំនួយខាងការអប់រំ និងបច្ចេកទេស និងកម្មវិធីសេវាកម្មទីប្រឹក្សាក្នុងវិស័យមួយចំនួន ។

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តសហប្រតិបត្តិការ និងគាំទ្រអង្គការក្រៅរដ្ឋាភិបាលកម្ពុជា ក្នុងការប្រតិបត្តិការសកម្មភាពរបស់ពួកគេ ដើម្បីលើកតម្កើង និងការពារសិទ្ធិមនុស្ស ។

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស បានបន្តចូលរួមជាមួយយន្តការរបស់អង្គការសហប្រជាជាតិមួយចំនួន និងសម្របសម្រួលជាមួយប្រទេសផ្តល់ជំនួយ ទាក់ទិននឹងបញ្ហាសិទ្ធិមនុស្ស និងនីតិរដ្ឋ និងសកម្មភាពនិងការប្រជុំរបស់ក្រុមអង្គការសហប្រជាជាតិក្នុងប្រទេស ។

# សេចក្ដីផ្ដើម

១-	ការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ត្រូវបានបង្កើតឡើងស្របតាមសេចក្ដីសំរេចចិត្តលេខ ១៩៩៣/៦ របស់គណៈកម្មការសិទ្ធិមនុស្ស ដែលបានប្រគល់ឱ្យការិយាល័យបំពេញសកម្មភាពដូចតទៅ:

(ក) គ្រប់គ្រងការអនុវត្តន៍ជំនួយអប់រំ និងបច្ចេកទេស និងកម្មវិធីសេវាកម្មប្រឹក្សា និងធានាការបន្តជំនួយ និងកម្មវិធីនេះ ។

(ខ) ជួយដល់រដ្ឋាភិបាលកម្ពុជា តាមការសុំរបស់រដ្ឋាភិបាលនេះ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនស្របតាមឯកសារសិទ្ធិមនុស្សនានាដែលខ្លួនបានចូលជាភាគី រួមមានការរៀបចំរបាយការណ៍ជូនអង្គការត្រួតពិនិត្យសន្ធិសញ្ញាមានពាក់ព័ន្ធ ។

(គ) ផ្ដល់ការគាំទ្រដល់ក្រុមសិទ្ធិមនុស្សពិតប្រាកដនៅក្នុងប្រទេសកម្ពុជា ។

(ឃ) រួមចំណែកក្នុងការបង្កើត និង/ឬពង្រឹងស្ថាប័នជាតិ សំរាប់ការលើកតម្កើង និងការការពារសិទ្ធិមនុស្ស ។

(ង) បន្តជួយធ្វើសេចក្ដីព្រាង និងអនុវត្តន៍ច្បាប់ ដើម្បីលើកតម្កើង និងការពារសិទ្ធិមនុស្ស ។

(ច) បន្តជួយហ្វឹកហ្វឺនអ្នកទទួលខុសត្រូវការគ្រប់គ្រងផ្នែកយុត្តិធម៌ ។

២.	ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ក៏ជួយលោកតំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ក្នុងការប្រតិបត្តិកិច្ចការរបស់លោក ដូចដែលបានផ្តល់ ជូនលោកដោយសេចក្តីសំរេចចិត្តនានា របស់មហាសន្និបាត និងរបស់គណៈកម្មការ សិទ្ធិមនុស្ស ។

៣.	ក្នុងរបាយការណ៍នេះ មានពតិមានស្តីពីតួនាទី និងលទ្ធផលសំរេចបានដោយការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ពីខែមករាឆ្នាំ ២០០៣ ដល់ខែមិថុនាឆ្នាំ ២០០៣ ក្នុងការជួយរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកតម្កើង និងការការពារសិទ្ធិមនុស្ស ។ របាយការណ៍ បានរៀបចំឡើងស្របតាមសេចក្តីសំរេចចិត្តរបស់មហាសន្និបាត A/RES/57/225 អនុម័តនៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០០២ ។ ពតិមានស្តីពីការងាររបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ពីខែកក្កដាឆ្នាំ២០០២ ដល់ខែធ្នូ ឆ្នាំ ២០០២ មានចែងនៅក្នុងរបាយការណ៍ដាក់ជូនគណៈកម្មការសិទ្ធិមនុស្ស ក្នុងសម័យប្រជុំលើកទី ៥៩ (E/CN.4/2003/113) ។ នៅក្នុងសេចក្តីសំរេចចិត្ត ២០០៣/៧៩ គណៈកម្មាការក៏បានសុំឱ្យលោកអគ្គលេខាធិការរាយការណ៍ជូនសម័យប្រជុំលើកទី ៦០ របស់ខ្លួនស្តីពីតួនាទី និងលទ្ធផលសំរេចបានរបស់ការិយាល័យផងដែរ ។

៤.	ក្នុងខែកុម្ភៈ ឆ្នាំ ២០០២ ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និងរាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចព្រមព្រៀងមួយ មានរយៈពេល ២ ឆ្នាំ សំរាប់ការអនុវត្តកម្មវិធីនៃកិច្ចសហប្រតិបត្តិការបច្ចេកទេសស្តីពីសិទ្ធិមនុស្ស ។ អនុស្សរណៈនេះ រួមមានវិស័យនៃកិច្ចសហប្រតិបត្តិការដូចតទៅៈ ការបន្តផ្តល់ជំនួយដល់រដ្ឋាភិបាលក្នុងការលើកតម្កើង និងការការពារសិទ្ធិមនុស្ស ការជំរុញកាន់តែខ្លាំងថែមទៀត ទំហំសិទ្ធិមនុស្សទៅក្នុងផ្នែកអប់រំ សុខាភិបាល កម្មវិធីអភិវឌ្ឍន៍ឯទៀត ការផ្តល់ការគាំទ្រផ្នែកបច្ចេកទេសសំ រាប់កម្មវិធីកែទម្រង់របស់រដ្ឋាភិបាល រួមមានការកែទម្រង់ក្នុងវិស័យនៃការគ្រប់គ្រងផ្នែកយុត្តិធម៌ និងកិច្ចដំណើរការធ្វើច្បាប់ ការលើកទឹកចិត្តការចូលរួមរបស់សង្គមស៊ីវិល និងការជំរុញការអប់រំជាសាធារណៈនៃលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស ជាពិសេសក្នុងវិស័យសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងការផ្តល់តាមការ ស្នើសុំរបស់រដ្ឋាភិបាល នូវជំនួយបច្ចេកទេស និងទីប្រឹក្សាក្នុងការបំពេញការទទួលខុសត្រូវរបស់ខ្លួន រួមមានការដាក់ជូនរបាយការណ៍ដើម្បីបំពេញកាតព្វកិច្ចសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន ។

៥. កម្មវិធីរបស់ការិយាល័យ គឺអនុវត្ត ដោយសហប្រតិបត្តិការជាមួយស្ថាប័នមួយចំនួនដែលទទួលខុសត្រូវខាងសិទ្ធិមនុស្ស រួមមានគណៈកម្មការសិទ្ធមនុស្សនិងទទួលពាក្យបណ្តឹង និងគណៈកម្មការនិតិកម្មរបស់រដ្ឋសភា និងព្រឹទ្ធសភា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តុលាការ ការិយាល័យអគ្គព្រះរាជអាជ្ញា គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជារបស់រដ្ឋាភិបាល នាយកដ្ឋានពន្ធនាគារ ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្មនិងសំណង់ ក្រសួងកសិកម្មរុក្ខានិងជលផល ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន និងក្រសួងសង្គមកិច្ចនិងការងារ និងមហាវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ ការិយាល័យក៏បានសហការជាមួយអង្គការក្រៅរដ្ឋាភិបាលធ្វើការខាងបញ្ហាសិទ្ធិមនុស្ស ច្បាប់ និងអភិវឌ្ឍន៍ មួយចំនួនធំផងដែរ ។

៦. ការពិនិត្យពីខាងក្រៅនូវតួនាទីរបស់ការិយាល័យ និងកម្មវិធីនិងអាទិភាពនានានាពេលអនាគតរបស់ខ្លួន មានគំរោងនឹងរៀបចំធ្វើនៅក្នុងខែតុលា ។ ការដាក់បន្ទុកសមត្ថកិច្ចរបស់ការិយាល័យ ផ្តោតទៅលើទិសដៅ កម្មវិធី រចនាសម្ព័ន្ធ របស់ការិយាល័យ និងតួនាទីក្នុងកិច្ចសហប្រតិបត្តិការរបស់ខ្លួនក្នុងដំណាក់កាលអនាគតនៃប្រតិបត្តិការរបស់ខ្លួន ចាប់ពីខែមីនា ឆ្នាំ ២០០៤ ទៅ នៅពេលបន្តអនុស្សរណៈនៃកិច្ចព្រមព្រៀងបច្ចុប្បន្ន ។

## II. ការជួយលោកតំណាងពិសេសរបស់លោកអគ្គលេខាធិការ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

៧. ក្នុងរយៈពេលនៃការធ្វើរបាយការណ៍នេះ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានផ្តល់ជូនលោកតំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា នូវពត៌មានស្តីពីបញ្ហានៃការយកចិត្តទុកដាក់នានា ជាពិសេសក្នុងវិស័យនៃការកែទម្រង់តុលាការ ការបោះឆ្នោតរដ្ឋសភាខែកក្កដាឆ្នាំ ២០០៣ ការដាក់កំហិតដល់សេរីភាពនៃការសំដែងមតិ ធ្វើសមាគម និងការប្រជុំ ការទទួលបានពត៌មាន ការប្រើប្រាស់កម្លាំងដោយហួសហេតុរបស់កងនគរបាល បញ្ហាដីធ្លីនិងព្រៃឈើ ស្ថានភាព

និងការកែទម្រង់ពន្ធនាគារ ការទាក់ទងរវាងនគរបាលនិងតុលាការ ជំនួយការច្បាប់ និងបញ្ហាយុត្តិធម៌ព្រហ្មទ័ណ្ឌមួយចំនួន ។

៨. ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស បានជួយសំរួលដល់បេសកកម្មលើកទី ៨ និងទី ៩ របស់លោកតំណាងពិសេសនៅកម្ពុជា ស្របតាមអាណត្តិរបស់លោក ដើម្បីរក្សាការទាក់ទងជាមួយរដ្ឋាភិបាលនិងប្រជាពលរដ្ឋកម្ពុជា ដឹកនាំនិងសំរបសំរួលវត្តមានសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅកម្ពុជា និងជួយរដ្ឋាភិបាលក្នុងការលើកតម្កើងនិងការការពារសិទ្ធិមនុស្ស ។ លទ្ធផលនៃបេសកកម្មទាំងនេះដែលបានធ្វើឡើងរវាងពីថ្ងៃទី ២៥ ខែកុម្ភៈ ដល់ថ្ងៃទី ៤ ខែមីនា និងថ្ងៃទី ៣០ ខែមិថុនា ដល់ថ្ងៃទី ៨ ខែកក្កដា ជាបន្តបន្ទាប់ មានសង្ខេបនៅក្នុងរបាយការណ៍របស់លោកជូនមហាសន្និបាត (...............) ។ ក្នុងពេលបេសកកម្មរបស់លោកលោកតំណាងពិសេសបានបន្តផ្តល់ការយកចិត្តទុកដាក់ទៅលើការបោះឆ្នោតនាពេលខាងមុខ និងការកែទម្រង់ច្បាប់និងតុលាការ និងចាប់ធ្វើការលើបញ្ហាដីសម្បទានផ្តល់ឱ្យសំរាប់ធ្វើកសិកម្ម និងបច្ច័យរបស់វាទៅសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋនៅទីនោះ ។ ការិយាល័យបានរៀបចំឯកសារពន្យល់សង្ខេប ដោយសព្វមុខមួយសំរាប់លោកតំណាងពិសេស ដើម្បីសំរួលដល់ទស្សនៈកិច្ចរបស់លោក និងបានជួយលោកក្នុងការរៀបចំរបាយការណ៍របស់លោកជូនមហាសន្និបាត និងគណៈកម្មការសិទ្ធិមនុស្ស ។

៩. ក្នុងពេលទស្សនៈកិច្ចលើកទី ៨ លោកតំណាងពិសេសបានស្វែងយល់បញ្ហាបន្ថែមស្តីពីស្ថានភាពសិទ្ធិមនុស្ស និងបានពិភាក្សាជាមួយអាជ្ញាធរនានា អំពីរបាយការណ៍របស់លោកមុននឹងដាក់ជូនសម័យប្រជុំលើកទី ៥៩ របស់គណៈ កម្មការសិទ្ធិមនុស្ស។ បេសកកម្ម លើកទី ៩ របស់លោកគឺដើម្បីរៀបចំរបាយការណ៍ជូនសម័យប្រជុំលើកទី ៥៨ របស់មហាសន្និបាត ។ នៅពេលបញ្ចប់បេសកកម្ម លោកបានចេញផ្សាយរបាយការណ៍ទី ១ នៃ របាយការណ៍ ចំនួន ២ ទាក់ទិនទៅនឹងការបោះឆ្នោតរដ្ឋសភា ។

## II. តួនាទីរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយរដ្ឋាភិបាលនិងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកតម្កើងនិងការការពារសិទ្ធិមនុស្ស

## ក. ទិសដៅទូទៅ

១០. ក្នុងការជួយរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកតម្កើងនិងការការពារសិទ្ធិមនុស្ស ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា មានបំណងរួមចំណែកឆ្ពោះទៅកាន់ទិសដៅយូរអង្វែងនៃសង្គមកម្ពុជាមួយឈរលើការគោរពសិទ្ធិមនុស្ស ក្រោមនីតិរដ្ឋ និងវត្តមាននៃសង្គមស៊ីវិលមួយដ៏ខ្លាំង ដែលអាចប្រតិបត្តិការស្របតាមបទបញ្ញត្តិនៃសេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និង អង្គការសង្គម ដើម្បីលើកតម្កើងនិងការពារ សិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន ដែលត្រូវបានទទួលស្គាល់ជាសកល[១] ។ យុទ្ធសាស្ត្របញ្ចូលគ្នាគឺនីតិរដ្ឋ និង សិទ្ធិមនុស្សធ្វើការ ស្របគ្នាលើបញ្ហាបន្ទាន់នានា ដើម្បីបន្តទិសដៅយូរអង្វែងនៃការជួយបង្កើតនិងពង្រឹង ស្ថាប័នដើម្បីការពារសុវត្ថិភាពនិងធានាការគោរពសិទ្ធិមនុស្ស នាពេលះនាគត ។

១១. ឧបតសគ្គនៅមានច្រើនក្នុងកិច្ចខិតខំដើម្បីជំរុញសិទ្ធិមនុស្ស ស្របតាមនីតិរដ្ឋ។ តុលាការឯការជ្យមួយនៅមិនទាន់បានបង្កើតឡើងនៅឡើយទេ ហើយនៅមានការពិនិត្យការរំលោភរបស់អំណាចនីតិប្រតិបត្តិមិនគ្រប់គ្រាន់ បណ្តាលមកពីការខ្វះតម្លាភាពនៃយន្តការក្នុងចំណាត់ការប្រតិបត្តិ និងការអភិវឌ្ឍន៏ការទទួលខុសត្រូវមិនសមស្រប ។ និទ័ណ្ឌភាព និងអំពើពុករលួយ ធ្វើឱ្យឱនថយដល់កិច្ចខិតខំនៃការកែទម្រង់ ។

១២. ការិយាល័យបានបន្តសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយអង្គការក្រៅរដ្ឋាភិបាលកម្ពុជានានា និងក្រុមសង្គមស៊ីវិលដទៃទៀត ដើម្បីជំរុញនយោបាយ និងការប្រព្រឹត្ត យោលទៅតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិនៃប្រទេសកម្ពុជា និងដើម្បីជួយដល់កិច្ចខិតខំរបស់ពួកគេដើម្បីធានា ដល់ការដោះស្រាយសំរាប់ជនរងគ្រោះដោយសារការរំលោភផ្សេងៗ និងជួយឱ្យបានទូលំទូលាយថែមទៀតលើបញ្ហាច្បាប់ និងនយោបាយ ដែលជាប់ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ។ បុគ្គលិកបានចូលរួមប្រជុំជាទៀងទាត់ជាមួយគណៈកម្មាធិការប្រតិកម្មសិទ្ធមនុស្សកម្ពុជា ដែលមាន អង្គការចំនួន ១៨បញ្ចូលគ្នា

[១] A/RES/53/144, ថ្ងៃទី ៨ ខែមីនា ឆ្នាំ ១៩៩៩ ។

ដែលបានកំណត់ការប្រជុំគ្នាជាទៀងទាត់ និងសំរបសំរួលការងារក្នុងបញ្ហា សិទ្ធិមនុស្ស និងក្នុងការប្រជុំប្រចាំខែនៃក្រុមវេទិកាការងារអង្គការក្រៅរដ្ឋាភិបាលស្តីពីបរិស្ថាន ។

### ខ. ការការពារសិទ្ធិមនុស្ស: ការឃ្លាំមើល កាស៊ើបអង្កេត និងការធ្វើរបាយការណ៍

១៣. ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តឃ្លាំមើលស្ថានភាពសិទ្ធិមនុស្សនៅទូទាំងប្រទេស ស៊ើបអង្កេតលើរបាយការណ៍ពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងចងក្រងជាឯកសារលំនាំទាំងឡាយដែលនាំទៅឱ្យមានការរំលោភបែបនេះ ។ ការិយាល័យបានផ្តល់ជាទៀងទាត់សេចក្តីព្រួយបារម្ភរបស់ខ្លួននូវពតិមានដល់អាជ្ញាធររដ្ឋាភិបាលខេត្ត និងជាតិ និងបានស្នើវិធីដោះស្រាយ ។ ការិយាល័យក៏នៅតែរក្សាការទាក់ទងគ្នា ជាទៀងទាត់ជាមួយសមាជិករដ្ឋសភា តុលាការ អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍អន្តរជាតិ អំពីបញ្ហាទាំងនេះ ។

១៤. ក្នុងរយៈពេលនៃការធ្វើរបាយការណ៍នេះ ការិយាល័យបានផ្តល់ការយកចិត្តទុកដាក់ជាពិសេសទៅលើការស៊ើបអង្កេតព្រឹត្តិការណ៍ទាក់ទងទៅនឹងកុប្បកម្មដោយទ្រង់ទ្រាយធំ ដែលបានកើតឡើងនៅក្នុងទីក្រុងភ្នំពេញ នៅថ្ងៃ ២៩ ខែមករា ការណើឃាតកម្មចំនួន ៤ នៅក្នុងទីក្រុងភ្នំពេញ ទៅលើអ្នកនយោបាយ លោកសង្ឃ និងតុលាការ ថ្នាក់ខ្ពស់ ការចាប់ខ្លួននិងការឃុំខ្លួនសកម្មជនប្រឆាំង និងរបាយការណ៍ស្តីពីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនានា រួមមានឃាតកម្មឬការស្លាប់ដោយសង្ស័យថា បណ្តាលមកពីមូលហេតុនយោបាយ។ ក្នុងថ្ងៃភ្លាមៗ បន្ទាប់ពីកុប្បកម្មខែមករា បុគ្គលិកបានប្រមូលពតិមានទាក់ទិននឹងការរបួស ការចាប់ខ្លួន ការស៊ើបអង្កេត និងការបិទស្ថានីយវិទ្យុឯករាជ្យមួយ ។ បុគ្គលិកបានតាមដានយ៉ាងជិតស្និទ្ធការវិវឌ្ឍន៍នៃករណីទាក់ទិននឹង អ្នកដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសទាក់ទិននឹងកុប្បកម្ម និងបានបញ្ជូនទៅកាន់តុលាការ រាជធានីភ្នំពេញ ។ ការិយាល័យក៏បានបន្តឃ្លាំមើលបច្ច័យនៃការសម្លាប់លោកសង្ឃថ្នាក់ខ្ពស់ សម ប៊ុនធឿន កាលពីថ្ងៃទី ៦ ខែកុម្ភៈ ទីប្រឹក្សាគណបក្សហ៊្វុនស៊ីនប៉ិច ឱម រដ្ឋសាឪ កាលពីថ្ងៃទី ១៨ ខែកុម្ភៈ ក្រឡាបញ្ជីសា លាឧទ្ធរណ៍ ឈឹម ដារ៉ា កាលពីថ្ងៃទី ១០ ខែមេសា និងចៅក្រមតុលាការ សុខសេដ្ឋាមុនី កាលពីថ្ងៃទី ២៣ ខែ មេសា ។ បុគ្គលិកបានធ្វើការស៊ើបអង្កេតដល់ទីកន្លែង ទាក់ទងជាមួយតុលាការ ទស្សនាពន្ធនាគារ និងប្រជុំជាមួយមន្ត្រីរដ្ឋាភិបាល និងមន្ត្រីអនុវត្តច្បាប់ ។

១៥. ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តទទួលពាក្យបណ្តឹងពីសាធារណជន ស្តីពីការចោទប្រកាន់ពីការរំលោភសិទ្ធិមនុស្ស ។ ការិយាល័យបានចាត់វិធានការជាពិសេស លើករណីនៃការរំលោភនិងការបំភិតបំភ័យចំពោះសកម្មជនគណបក្សនយោបាយ ជម្លោះដីធ្លីនិងការដណ្តើមយកដី ទារុណកម្មនិងប្រព្រឹត្តកម្មឃោរឃៅ អមនុស្សធម៌ ឬឱនថយ នៅក្នុងកន្លែងឃុំឃាំង និងការរំលោភធ្ងន់ធ្ងរលើការធានានៃកិច្ចដំណើរការព្រហ្មទណ្ឌ ។ ការិយាល័យបានបន្តតាមដានការងារកាលពីលើកមុនស្តីពីការចងព្យួរគ្នាតាមដងផ្លូវ (ការសម្លាប់ដោយហ្វូងមនុស្ស) និងស្ថានភាពពន្ធនាគារ បន្តស៊ើបអង្កេតករណីដែលនៅមិនទាន់ដោះស្រាយ និងបានជួយអង្គការក្រៅរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សឱ្យបំពេញការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ។ ការិយាល័យក៏បានជួយពួកអ្នកការពារក្តីខាងសិទ្ធិមនុស្ស ដែលប្រឈមមុខនឹងការគំរាមកំហែងដល់សុវត្ថិភាពរបស់ពួកគេ ។

## គ. កម្មវិធីខាងការបោះឆ្នោត

១៦. ក្នុងខែមីនា ឆ្នាំ ២០០៣ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបង្កើតកម្មវិធីមួយទាក់ទិននឹងការបោះឆ្នោតរដ្ឋសភាខែកក្កដា ដើម្បីដោះស្រាយឧបសគ្គចំបងៗ ដែលស្ថិតមាននៅក្នុងការបង្កើតឱកាសស្មើគ្នាសំរាប់គណបក្សនយោបាយទាំងអស់ ឱ្យមានកិច្ចដំណើរការបោះឆ្នោតដោយតម្លាភាពមួយគ្រប់គ្រងដោយស្ថាប័នរដ្ឋអព្យាក្រិត និងបរិយាកាសនយោបាយមួយដែលគ្មានអំពើហឹង្សា និងការបំភិតបំភ័យ ។ ការិយាល័យបានផ្តល់យោបល់ដល់សេចក្តីព្រាងច្បាប់បោះឆ្នោត និងបទបញ្ជានានា ដើម្បីជួយក្នុងការអភិវឌ្ឍន៍ក្របខ័ណ្ឌច្បាប់មួយសមស្របទៅនឹងបទដ្ឋានអន្តរជាតិ ។ ការិយាល័យក៏បានបង្កើតក្រុមចល័តចំនួន ៣ ក្រុម ដើម្បីស៊ើបអង្កេតលើរបាយការណ៍នានា នៃការរំលោភសិទ្ធិមនុស្សទាក់ទិននឹងការបោះឆ្នោតនៅទូទាំងប្រទេស និងដើម្បីឃ្លាំមើលស្ថានភាពនយោបាយទូទៅ ។ អ្នកវិភាគការបោះឆ្នោតម្នាក់ និងអ្នកឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិម្នាក់ បានចាប់ផ្តើមធ្វើការនៅក្នុងខែមិថុនា ដោយអ្នកចុងក្រោយនេះធ្វើការនៅការិយាល័យខេត្តកំពង់ចាម ។

១៧. ការិយាល័យបានលើកឡើងជាបន្តបន្ទាប់ ការដាក់កំហិតលើសេរីភាពក្នុងការសំដែងមតិ និងការប្រជុំជាបញ្ហានៃការយកចិត្តទុកដាក់ជាពិសេសនានា ជាមួយអាជ្ញាធរមានពាក់ព័ន្ធនៅក្នុងខែមុនការបោះ ឆ្នោត។ មានការព្រួយបារម្ភជាប្រចាំក្នុងចំណោមតួអង្គ និងស្ថាប័នរដ្ឋ ថាការទិតៀនរដ្ឋាភិបាលអាចនាំទៅឱ្យមានបទព្រហ្មទ័ណ្ឌកើតឡើង និងថាពត៌មានពីគណបក្សនយោបាយមិនអាចផ្សព្វផ្សាយបានទេក្រៅពីរយៈពេលផ្លូវការនៃយុទ្ធនាការបោះឆ្នោត ។ ក្នុងខែមករា ការិយាល័យបានលើកបញ្ហាមួយចំនួនពាក់ព័ន្ធដល់ការចាប់និងឃុំខ្លួនសកម្មជនគណបក្សប្រឆាំងមួយរយៈពេលខ្លីតែខុសច្បាប់ តាមដឹងថាបណ្តាលមកពីបានធ្វើការឃោសនានៅរយៈពេលចុះឈ្មោះអ្នកបោះឆ្នោត ហើយបានផ្តល់ករណីទាំងនេះដល់អាជ្ញធរមូលដ្ឋាន ។ ការិយាល័យបានសុំឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតធានាថាចេញបញ្ជាជាបន្ទាន់ភ្លាមដល់អាជ្ញាធរគ្រប់ជាន់ថ្នាក់ បញ្ជាក់ច្បាស់ថា សកម្មជននយោបាយមិនត្រូវបានចាប់ឬឃុំខ្លួន ដោយសារតែសកម្មភាពនយោបាយដោយស្របច្បាប់នោះទេ ។ ការិយាល័យក៏បានលើកឡើងជាបន្តបន្ទាប់សេចក្តីព្រួយបារម្ភរបស់ខ្លួនជាមួយក្រសួងមហាផ្ទៃ នគរបាល និងអាជ្ញាធរក្រុង ស្តីពីការបន្តឹងលើសេរីភាពក្នុងការប្រជុំ និងស្តីពី ការប្រើកម្លាំងហួសហេតុ ដើម្បីបំបែកការធ្វើបាតុកម្មដោយអត់ច្បាប់ ។

១៨. បុគ្គលិកការិយាល័យទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានចូលរួមប្រជុំប្រចាំខែរវាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសហគមន៍ទូតនិងផ្តល់ជំនួយ ដោយបានរាយការណ៍សង្ខេបជូនអ្នកចូលរួមអំពីសេចក្តីព្រួយបារម្ភផ្នែកសិទ្ធិមនុស្សទាក់ទិននឹងការបោះឆ្នោត និងផ្តល់ជូនពត៌មានអំពីការរំលោភ ធ្ងន់ធ្ងរនានា ។ បុគ្គលិកបានជួបប្រជុំជាទៀងទាត់ ជាមួយតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីលើកករណីពិសេស និងបញ្ហានៃការយកចិត្តទុកដាក់ដទៃទៀត ជាពិសេសស្តីពីការចាត់ការលើបណ្តឹងស្តីពីការបំភិតបំភ័យនិងហឹង្សា ។ ការិយាល័យក៏បានទាញការយកចិត្តទុកដាក់ របស់គណៈកម្មាធិការជាតិរៀបចំ ការបោះឆ្នោត ពីការព្រួយបារម្ភរបស់ខ្លួនស្តីពីទិដ្ឋភាពខ្លះ នៃសេចក្តីព្រាងបទបញ្ជានិងនីតិវិធី សំរាប់ការបោះឆ្នោតដែលមានសក្តានុពលដាក់កំហិតដល់សេរីភាពក្នុងការសំដែងមតិ ការប្រជុំ និងការចូលរួមចំណែកក្នុងកិច្ចការសាធារណៈ ។ ក្នុងខែមេសា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានធ្វើវិសោធនកម្មលើបទបញ្ជាមួយចំនួន ដោយបានពិចារណាការស្នើយោបល់របស់ការិយាល័យ និងបានចែងច្បាស់អំពីសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងការធ្វើសកម្មភាពនយោបាយស្របច្បាប់នៅគ្រប់ពេលវេលា ។

១៩.  ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធមនុស្សប្រចាំកម្ពុជា បានបន្តឃ្លាំមើលការខិតខំក្នុងការអនុវត្តច្បាប់ និងការវិនិច្ឆ័យក្តីរបស់តុលាការ ទាក់ទិនទៅនឹងករណីឃាតកម្ម និងការស្លាប់គួរឱ្យសង្ស័យជាច្រើន ដែលសង្ស័យថាបណ្តាលមកពីមូលហេតុនយោបាយ និងលើទ្រង់ទ្រាយដទៃទៀតនៃអំពើហឹង្សា និងការបំភិតបំភ័យប្រឆាំងទៅលើសកម្មជនគណបក្សនយោបាយ ។ ការិយាល័យបានបន្តអភិវឌ្ឍន៍ទិន្នន័យដើម្បីកត់ត្រាទុកហឹង្សាខាងសិទ្ធិមនុស្សទាក់ទិនទៅនឹងការបោះឆ្នោត ដែលត្រូវបានរាយការណ៍ឱ្យដឹង និងបានចែករំ លែកពតិមានជាមួយតួអង្គមានពាក់ព័ន្ធទាំងឡាយ ។ បុគ្គលិកបានជួបប្រជុំជាមួយតំណាងគណបក្សនយោបាយធំ៧ទាំងអស់ និងបានរាយការណ៍សង្ខេបជូនអង្គទូត សហគមន៍ផ្តល់ជំនួយ និងអង្គការអន្តរជាតិនានា ។ ការិយាល័យបានបន្តកិច្ចខិតខំសំរបសំរួលជាមួយអង្គការក្រៅរដ្ឋាភិបាល ខាងការបោះឆ្នោត និងសិទ្ធិមនុស្ស ក្នុងស្រុក រៀបចំឱ្យមានការប្រជុំជាទៀងទាត់ ដើម្បីពិភាក្សាបញ្ហាដែលយកចិត្តទុកដាក់រួម ។ កិច្ចសហប្រតិបត្តិការនេះ បានពង្រីកទៅដល់ខេត្ត ដោយបុគ្គលិកធ្វើការជួយគាំទ្រដល់អង្គការក្រៅរដ្ឋាភិបាល អំពីការឃ្លាំ មើល និងការស៊ើបអង្កេត ។

## ឃ. គំរោងការណ៍ដីធ្លី

២០.  បញ្ហាដីធ្លីនៅតែជាប្រភពធំមួយនៃជម្លោះ និងការរំលោភសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ដែលជាប្រទេសមួយដែលមុនស្សជាង ៨០ ភាគរយរស់នៅតំបន់ជនបទ និងពឹងពាក់លើកសិកម្មសំរាប់ការរស់នៅរបស់ពួកគេ និងដែលបញ្ហាអត់មានដីបានក្លាយជាបញ្ហាចេះតែកើនឡើង ។ ដោយមានការស្មុគ្រស្មាញខាងផ្លូវច្បាប់ រដ្ឋបាល និងសង្គម អំពីបញ្ហាទាក់ទិននឹងដីធ្លី ការិយាល័យបានសំរេចផ្តោតការយកចិត្តទុកដាក់ជាបឋមទៅលើបច្ច័យនៃការផ្តល់សម្បទានដីសំរាប់កសិកម្ម ។ បន្ទាប់មកបានពង្រីក ដោយបញ្ចូលចំការកសិកម្មដោយទ្រង់ទ្រាយធំ ។ ការិយាល័យបានប្រមូលពតិមាន ពិនិត្យមើលឡើងវិញឯកសារ និងចុះទៅធ្វើការដល់ទីកន្លែងនៃចំការកសិកម្មទ្រង់ទ្រាយធំមួយចំនួន[២] ដើម្បីវាយតម្លៃអំពីផលប៉ះពាល់របស់វា លើសិទ្ធិមនុស្សនៃប្រជាពលរដ្ឋមូលដ្ឋាន ។ បុគ្គលិកយើងក៏បានប្រមូលទិន្នន័យស្តីការគោរពច្បាប់ភូមិបាលឆ្នាំ ២០០១

[២] ចំការទាំងនេះ បានធ្វើដោយក្រុមហ៊ុនហ្វូលរម៉ានុយហ្វាក់ទូរីង (ក្នុងខេត្តស្ទឹងត្រែង) ហែននីង (ក្នុងខេត្តកំពង់ស្ពឺ) ភាពីម៉ិច (ក្នុងខេត្តពោធិសាត់ និងកំពង់ឆ្នាំង) ម៉ុងឫទ្ធី (ក្រុងព្រះសីហនុ) អាក្រុស្តារ (ក្នុងខេត្តកំពង់ចាម) ក្រុមហ៊ុនចំការកៅស៊ូរដ្ឋ ជប់ (ក្នុងខេត្តកំពង់ធំ) ។

និងល័ក្ខខ័ណ្ឌនៃកិច្ចសន្យា ពីសំណាក់អ្នកទទួលបានសម្បទានពាក់ព័ន្ធផងដែរ ។ ការសិក្សាបានកំណត់ថាត្រូវបញ្ចប់ក្នុងខែកក្កដា ឆ្នាំ ២០០៣ ។ ការិយាល័យបានលើកការរកឃើញរបស់ខ្លួនជាមួយក្រសួងកសិកម្ម រុក្ខា និងជលផល និងបានផ្តល់អនុសាសន៍ឱ្យលប់ចោលកិច្ចសន្យាទាំងឡាយណា ដែលម្ចាស់សម្បទាន បានរំលោភច្បាប់ ឬបានបំពានយ៉ាងធ្ងន់ធ្ងរលើល័ក្ខខ័ណ្ឌនៃកិច្ចសន្យា ។

២១. បុគ្គលិកយើងក៏បានធ្វើការស៊ើបអង្កេត និងរៀបចំឯកសារស្តីពីជម្លោះដីធ្លីនៅស្រុកគាស់ក្រឡ ក្នុងខេត្តបាត់ដំបងផងដែរ ។ ការសិក្សាដោយលំអិតនៃករណីពិសេសទាំងនេះ គឺក្នុងបំណងជួយរៀបចំឯកសារ និងលើកឡើងបញ្ហាដែលកើតមានឡើងជាញឹកញាប់ ទាំងក្នុងការគ្រប់គ្រងដី និងយន្តកម្មសំរាប់ដោះស្រាយជម្លោះដីធ្លី និងការរំលោភសិទ្ធិមនុស្សពាក់ព័ន្ធ ។ នៅពេលបច្ចុប្បន្ននេះ ទាំងរចនាសម្ព័ន្ធគណៈកម្មការភូមិបាលបង្កើតឡើងនៅក្នុងខែកក្កដា ឆ្នាំ ២០០២ ទាំងតុលាការ ពុំបានធ្វើការដោយស្រសិទ្ធភាព ដើម្បីដោះស្រាយជម្លោះទាក់ទងនឹងដីធ្លី ឬការដោះស្រាយចំពោះការរំលោភសិទ្ធិមនុស្សដែលមានពាក់ព័ន្ធទេ ។ លើសពីនេះទៅទៀត ច្បាប់ភូមិបាលបានផ្តល់អំណាចដ៏ធំធេងទៅឱ្យផ្នែកនីតិប្រតិបត្តិរបស់រដ្ឋាភិបាល ដែលធ្វើការដោយពុំបានដល់កំរិតនៃតម្លាភាពសមរម ឬទទួលខុសត្រូវទេ ។ ការិយាល័យបានគាំទ្រឱ្យទទួលបានពត៌មានទាក់ទងនឹងសម្បទានដីច្រើនជាងនេះ ដូចជាកិច្ចសន្យានិងផែនទីជាដើម ដែលប្រជាពលរដ្ឋមិនដែលបានដឹងទោះបីវាជាបញ្ហានេះជាផលប្រយោជន៍សាធារណៈដ៏សំខាន់យ៉ាងណាក៏ដោយ ។ ការលំបាកក្នុងការទទួលពត៌មាននេះ បានគូសបញ្ជាក់លើកយកមកធ្វើជាគោលសំខាន់នៃសេចក្តីត្រូវការជាបន្ទាន់ ដើម្បីអភិវឌ្ឍន៍ការអនុវត្ត និងនយោបាយរដ្ឋបាលមានតម្លាភាពជាងនេះ និងដើម្បីអនុម័ត ច្បាប់សេរីភាពក្នុងការទទួលបានពត៌មាន ដែលនាំឱ្យតាមដានសកម្មភាពរបស់ផ្នែកប្រតិបត្តិ និងលើកទឹកចិត្តការទទួលខុសត្រូវធំជាងនេះ ។

២២. ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បន្តឃ្លាំមើលការអនុវត្តច្បាប់ភូមិបាលដែលនៅត្រូវទាមទារឱ្យអនុម័តអនុក្រឹត្យនិងសេចក្តីប្រកាសជាច្រើនទៀត ដើម្បីអាចអនុវត្តបទបញ្ញត្តិរបស់វាដោយពេញលេញបាន ។ ការិយាល័យបានផ្តល់អត្ថាធិប្បាយ ដើម្បីជួយក្នុងការរៀបចំអនុក្រឹត្យ ស្តីពីសម្បទានដើម្បីទិសដៅសង្គមកិច្ច ដែលត្រូវបានអនុម័ត នៅថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៣ និងបានលើកទឹកចិត្តឱ្យអនុវត្តឱ្យបានរហ័ស ។ កម្មវត្ថុនៃអនុក្រឹត្យនេះ គឺដើម្បីកំណត់ល័ក្ខខ័ណ្ឌ នីតិវិធី និងយន្តកម្ម ដើម្បីសម្បទាន

សង្គមកិច្ចសំរាប់ប្រើប្រាស់ជាលំនៅដ្ឋាន និង/ឬការដាំដុះចិញ្ចឹមជីវិត ។ ការិយាល័យបានផ្ដល់យោបល់ដល់ក្រសួងមានពាក់ព័ន្ធអំពីការផ្ដល់សម្បទានបែបនេះ ។ មានសេចក្ដីបារម្ភអំពីទីកន្លែងនៃដីត្រូវផ្ដល់ឱ្យសំរាប់សម្បទាន ដោយអនុក្រឹត្យមិនបានបញ្ជាក់អំពីកាតព្វកិច្ចរបស់រដ្ឋ ក្នុងការបង្កើតរចនាសម្ព័ន្ធ នៅក្នុងតំបន់សម្បទាន ដូចជាសាលារៀន សេវាថែរក្សាសុខភាព និងឱកាសមានធ្វើការងារសំរាប់ប្រជាពលរដ្ឋមាន ពាក់ព័ន្ធ។ ម្យ៉ាងទៀត មានសេចក្ដីបារម្ភអំពីទំហំតូចនៃដីដែលមានសំរាប់សម្បទានសង្គមកិច្ច ដោយដីភាគ ច្រើនដែលអាចនឹងសមស្របសំរាប់ទិសដៅសង្គមកិច្ច ឥឡូវត្រូវត្រួតត្រាដោយសម្បទាន ព្រៃឈើ ឬ កសិឧស្សាហកម្មដ៏ធំទូលាយអស់ហើយ ។ ការិយាល័យបានគាំទ្រ និងនឹងរួមចំណែកឆ្ពោះទៅឱ្យមាន ការរៀបចំ និងអនុម័តឱ្យបានឆាប់នូវអនុក្រឹត្យស្ដីពីសម្បទានដីសំរាប់ទិសដៅសេដ្ឋកិច្ច (ដែលកំពុងព្រាង ដោយក្រុមការងារមួយដែលមានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី) និងអនុក្រឹត្យស្ដីពីនីតិវិធីសំរាប់កាត់បន្ថយនិងការលើកលែងជាពិសេសនៃ សម្បទានដីដែលលើសពី ១០ ០០០ ហិកតា ។ ការិយាល័យបានផ្ដល់យោបល់ថានឹងពុំមានសម្បទានបន្ថែម ទៀតទេ ក្នុងពេលរង់ចាំការអនុម័តអនុក្រិត្យទាំងនេះ ។

២៣. ការិយាល័យបានទាក់ទងទៀងទាត់ជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិដែលធ្វើការអំពីបញ្ហាដីធ្លី និងព្រៃឈើដើម្បីពិភាក្សាបញ្ហានៃការព្រួយបារម្ភជាគន្លឹះ ដើម្បីសំរបសំរួលដល់កិច្ចខិតខំ និងដើម្បីជួយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលធ្វើការពីបញ្ហាព្រៃឈើ ដើម្បីពួកគេបំពេញភារកិច្ចក្នុងស្ថានភាពមានសុវត្ថិភាព ។

## ង. សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

២៤. ការងាររបស់គឺដើម្បីជំរុញការទទួលបានសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។ ការិយាល័យប្រចាំកម្ពុជាបានគាំទ្រឱ្យមាននយោបាយជាតិឈរលើមូលដ្ឋានកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ ទាក់ទងទៅនឹងវិស័យដូចជាការអភិវឌ្ឍន៍ទីក្រុង បរិដ្ឋាន ការកាត់បន្ថយភាពក្រីក្រ និងគ្រប់គ្រងធនធានធម្មជាតិ ជាដើម ។ ការិយាល័យបានិរះរក ជាពិសេសជាមួយតួអង្គជាតិ និងមូលដ្ឋាន នូវផ្លូវនិងមធ្យោបាយ ដើម្បីប្រែក្លាយបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ទៅជាវិធានការជាក់ស្ដែង ដើម្បីធានាថា សេចក្ដីបារម្ភពីសិទ្ធិមនុស្ស ត្រូវបាន

ដោះស្រាយដោយពេញលេញ ក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ជាតិ និងការសំរេចបាននូវទិសដៅអភិវឌ្ឍន៍សហសវត្ស ។

២៥. ការិយាល័យបានបន្តធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ជាពិសេសជាមួយគណៈកម្មាធិការអង្គការក្រៅរដ្ឋាភិបាល ស្តីពីការឃ្លាំមើលសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងសមាជិកគណៈកម្មាធិការនេះ ។ គណៈកម្មាធិការនេះ បានចេញរបាយការណ៍ស្របមួយនៅក្នុងខែកញ្ញា ឆ្នាំ ២០០២ ស្តីពីការប្រព្រឹត្តតាមកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ របស់ប្រទេសកម្ពុជា ។ ក្នុងរបាយការណ៍ បានលើកឡើងនូវអនុសាសន៍ជាក់ស្តែងមួយចំនួន ដើម្បីផ្តល់ពតិមានអំពីនយោបាយ និងការអនុវត្តថ្នាក់ជាតិ ដែលនឹងត្រូវដោះស្រាយដោយអ្នកធ្វើនយោបាយនិងអ្នកអនុវត្តជាតិ និងអន្តរជាតិក្នុងកិច្ចខិតខំរួមមួយ ដើម្បីប្រព្រឹត្តតាមកតិកាសញ្ញា ។ ការិយាល័យក៏បានស្វែងរកដើម្បីជួយដល់គណៈកម្មា ធិការសិទ្ធិមនុស្សកម្ពុជា ដើម្បីបញ្ចប់របាយការណ៍លើកដំបូងរបស់ប្រទេសកម្ពុជា ជូនគណៈកម្មាធិការសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។

២៦. ការិយាល័យបានបន្តលើកបញ្ហាតាំងលំនៅថ្មី និងស្ថានភាពរបស់ អ្នកសំណង់អនាធិបតេយ្យ និងអ្នកក្រីក្រក្នុងក្រុងនៅភ្នំពេញ ។ ការិយាល័យបានចូលរួមសិក្ខាសាលា ដែលរៀបចំដោយក្រុមអភិវឌ្ឍន៍ទីក្រុង និងបណ្តាញការងាររបស់អង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការលើបញ្ហាលំនៅដ្ឋាន និងអ្វីដែលមានការពាក់ព័ន្ធ សិក្ខាសាលានេះមានការគាំទ្ររបស់អង្គការខាងលំនៅដ្ឋានរបស់អង្គការសហប្រជាជាតិ ។ ការិយាល័យក៏បានបន្តការជាប់ពាក់ព័ន្ធក្នុងការងាររបស់ក្រុមរួបរួមសកម្មភាពខាងជលផលផងដែរ ដែលជាគំរោងការណ៍មួយទទួលជំនួយថវិការពីការិយាល័យប្រចាំកម្ពុជាតាមរយៈអង្គការវេទិការអង្គការក្រៅរដ្ឋាភិបាលនៃកម្ពុជា ដើម្បីជំរុញការយល់ដឹងផ្នែកច្បាប់ បណ្តាញការងារ និងគាំទ្រ ចំពោះសហគមន៍ធ្វើនេសាទនៅជុំវិញបឹង ទន្លេសាប ។

២៧. បុគ្គលិកក្នុងស្រុករបស់ការិយាល័យ និងការិយាល័យប្រចាំខេត្តបាត់ដំបង បានអភិវឌ្ឍន៍មេរៀនសំរាប់ការហ្វឹកហ្វឺនមូលដ្ឋាន ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលផ្តោតទៅលើសិទ្ធិទទួលបានការថែរក្សាសុខភាព ការអប់រំ និងលំនៅដ្ឋាន និងជីវភាពរស់នៅជាមូលដ្ឋាន ។

បុគ្គលិកការិយាល័យខេត្តបាត់ដំបង បានផ្ដល់ការហ្វឹកហ្វឺន រយៈមួយថ្ងៃជាច្រើនលើក ដល់អ្នកភូមិ និងប្រធានក្រុមប្រឹក្សាសង្កាត់ ក្នុងស្រុកនានានៃខេត្ត ជាពិសេស កន្លែងដែលមានបញ្ហាដីធ្លី ។ ការហ្វឹកហ្វឺនក៏ត្រូវបានផ្ដល់ឱ្យអង្គការក្រៅរដ្ឋាភិបាលដែលមានមូលដ្ឋាននៅបាត់ដំបងដែរ ។

## ច. គ្រោងការណ៍នីតិរដ្ឋ

### (i) តុលាការ និងការគ្រប់គ្រងផ្នែកយុត្តិធម៌

២៨. ការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តឃ្លាំមើលកិច្ចដំណើរការកែទម្រង់តុលាការ ដើម្បីបញ្ចូលគោលការណ៍ និងបទបញ្ញត្តិលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ និងគោលការណ៍ជាមូលដ្ឋាននៃឯករាជ្យភាពរបស់តុលាការ ទៅក្នុងច្បាប់និងការអនុវត្ត ។ ការិយាល័យបានគាំទ្រឱ្យមានការកែទម្រង់រចនាសម្ព័ន្ធរបស់ស្ថាប័នគន្លឹះនានា ដូចជាឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមជាដើម ។ ការិយាល័យរក្សាវត្តមានរបស់ខ្លួននៅក្នុងតុលាការក្រុងព្រះសីហនុ និងតុលាការរាជធានីភ្នំពេញ និងក៏នៅបន្តចំណងរបស់ខ្លួនជាមួយតុលាការដទៃទៀតផងដែរ តាមរយៈបុគ្គលិកប្រចាំការិយាល័យភ្នំពេញ ។ ការិយាល័យបានបន្តកិច្ចសហប្រតិបត្តិការជិតស្និទ្ធ ជាមួយតុលាការខេត្តបាត់ដំបងតាមរយៈការិយាល័យភូមិភាគរបស់ខ្លួន បន្ថែមដោយការចុះទៅមើលជាទៀងទាត់របស់បុគ្គលិកពីការិយាល័យថ្នាក់ជាតិ ។

២៩. ការិយាល័យបានបន្តជួយ និងឃ្លាំមើលតុលាការ ដើម្បីធានាការប្រព្រឹត្តតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ជាពិសេសតាមរយៈការអនុវត្តក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដែលហាក់ដូចនៅមិនទាន់មានចែងនៅក្នុងច្បាប់នៅឡើយ និងមានភាពមិនស្របគ្នាជាមួយបទដ្ឋានអន្តរជាតិ ។ បុគ្គលិកបានបានតាមសង្កេតមើលការកាត់ក្ដីសំខាន់ៗ រួមមានការកាត់ក្ដីទាក់ទិនទៅនឹងការជួញដូរមនុស្ស ទារុណកម្ម និងការសម្លាប់ដោយហ្វូងមនុស្ស ។ ការិយាល័យបានផ្ដល់យោបល់ស្ដីពីសិទ្ធិក្នុងកិច្ចដំណើរការត្រឹមត្រូវ និងនីតិវិធីនៃការកាត់ក្ដី និងបានដោះស្រាយបញ្ហាទាក់ទិនទៅនឹងតំណាងខាងច្បាប់ និងការទទួលបានយុត្តិធម៌ វិះរកដើម្បីជួយសំរួលដល់ការទាក់ទងរវាងជនជាប់ចោទ និងមេធាវីខាងច្បាប់ នៅពេលករណីធ្ងន់ធ្ងរត្រូវធ្វើ

ការវិនិច្ឆ័យនៅក្នុងតុលាការដោយគ្មានតំណាងខាងច្បាប់ ។ ការិយាល័យក៏បានឃ្លាំមើលការទាក់ទងរវាងនគរបាល-តុលាការ ដោយមានការខកខានជាប្រចាំដោយនគរបាលក្នុងការប្រតិបត្តិតាមបញ្ជារបស់តុលាការ ។

៣០. ការិយាល័យបានជួបប្រជុំជាទៀងទាត់ជាមួយសមាជិកតុលាការ អង្គការនីតិបញ្ញត្តិ និងរដ្ឋាភិបាល ដើម្បីពិភាក្សាបញ្ហាតុលាការ និងនយោបាយទូលំទូលាយ ទាក់ទិនទៅនឹងសិទ្ធិមនុស្ស ក្នុងការគ្រប់គ្រងផ្នែកយុត្តិធម៌ រួមមានការជួបជាមួយអ្នកច្បាប់ ចៅក្រម និងព្រះរាជអាជ្ញា ក្រុមប្រឹក្សាកែទម្រង់ច្បាប់ និងមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានគណៈកម្មការសភានានា ។ ក្នុងចំណោមកម្មវត្ថុនៃកិច្ចពិភាក្សា គឺបញ្ហាឯករាជ្យភាពរបស់តុលាការ ការកែទម្រង់ទាង់ទងនឹងអង្គការតុលាការ និងវិជ្ជាជីវៈខាងច្បាប់ ការព្រួយបារម្ភអំពីសន្តិសុខរបស់ចៅក្រមនិងបុគ្គលិកតុលាការ ការស្ទះករណីនៅក្នុងប្រព័ន្ធតុលាការ នយោបាយសំរេចក្តីនិងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ។ ការិយាល័យក៏បានធ្វើការដោយសហប្រតិបត្តិការជិតស្និទ្ធជាមួយអង្គការក្រៅរដ្ឋាភិបាលធ្វើការខាងបញ្ហាច្បាប់ និងការកែទម្រង់តុលាការផងដែរ ។

៣១. ការិយាល័យបានរៀបចំឯកសារដោយសព្វមុខមួយស្តីពីការកែទម្រង់ច្បាប់និងតុលាការ ដែលបានផ្តល់ជាទស្សនៈរួមមួយនៃការវិវឌ្ឍន៍ក្នុងទសវត្សកន្លងទៅនេះ សំរាប់ការប្រជុំពាក់កណ្តាលអាណត្តិនៃក្រុមប្រឹក្សាយោបល់កាលពីខែមករា ។ ការិយាល័យបានលើកឡើងជាថ្មី សេចក្តីបារម្ភដែលបានលើកឡើងដោយលោកតំណាងពិសេសនៅក្នុងរបាយការណ៍របស់លោកជូនមហាសន្និបាត និងគណៈកម្មាសិទ្ធិមនុស្ស និងបានគូសសង្កត់អំពីការខកខានរបស់រដ្ឋាភិបាលមិនបានបំពេញកិច្ចសន្យាចំនួន ៥ ដែលបានយល់ព្រមកាលពីខែមិថុនា ឆ្នាំ ២០០២ នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាយោបល់នៃប្រទេសផ្តល់ជំនួយ ។ ព្រំដែនពេលវេលាមួយនៃយុទ្ធសាស្ត្រនៃការកែទម្រង់ច្បាប់ និងតុលាការ ត្រូវបញ្ចប់នៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០០២ ក៏ដូចជាការកែរចនាសម្ព័ន្ធឡើងវិញនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ស្តីពីឋានៈរបស់ចៅក្រម និងព្រះរាជអាជ្ញាផងដែរ ។ ករណីនៃអំពើពុករលួយ ត្រូវតែស៊ើបអង្កេតនិងផ្តន្ទាទោសជាបន្ទាន់ ហើយច្បាប់ប្រឆាំងអំពើពុករលួយ ត្រូវដាក់ជូនរដ្ឋសភាមុនថ្ងៃ ៣០ ខែមិថុនា ឆ្នាំ ២០០៣ ។ ទោះបីជំហានខ្លះបានត្រូវធ្វើឡើងឆ្ពោះទៅបំពេញ កិច្ចសន្យានៅពេលសរសេររបាយការណ៍នេះក៏ដោយ ក៏ពុំទាន់មានករណីនៃអំពើពុករលួយណាមួយត្រូវបាន ផ្តន្ទាទោសនៅក្នុងតុលាការទេ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

រង់ចាំការកែទម្រង់ ហើយសេចក្តីព្រាងច្បាប់ ស្តីពីឋានៈរបស់ចៅក្រមនិងព្រះរាជអាជ្ញា មិនទាន់បានដាក់ជូនរដ្ឋសភានៅឡើយទេ ។

៣២. ថ្មីៗនេះ ការិយាល័យបានផ្តួចផ្តើមគំនិតឱ្យមានការពិភាក្សាគ្នាមួយ អំពីជំនួយការ ច្បាប់ជាមួយក្រសួងយុត្តិធម៌ អង្គភាពជំនួយការច្បាប់របស់គណៈមេធាវី និងអង្គការក្រៅរដ្ឋាភិបាល មានពាក់ព័ន្ធ ។ ការផ្តល់ជំនួយការច្បាប់ បច្ចុប្បន្នស្ថិតនៅក្នុងដៃគណៈមេធាវី និងអង្គការក្រៅរដ្ឋាភិបាល ដោយអង្គការទាំង ពីរពុំបានទទួលថវិការរបស់រដ្ឋទេ ។ ការិយាល័យកំពុងប្រមូលទិន្នន័យ ដើម្បីធ្វើរបាយការណ៍មួយពណ៌នាអំពីស្ថានភាពបច្ចុប្បន្នទាក់ទងទៅនឹងតំណាងខាងច្បាប់នៅចំពោះមុខតុលាការ និងការទទួលបានជំនួយផ្នែកច្បាប់ ទូទៅជាងនេះ ក្នុងទិសដៅធ្វើការវាយតម្លៃសេចក្តីត្រូវការរបស់ប្រទេសកម្ពុជា ក្នុងការធានា ដល់ប្រជាពលរដ្ឋភាគច្រើន អាចប្រើប្រាស់ប្រព័ន្ធយុត្តិធម៌បាន ចំពោះអ្នកដែលមិនមានលទ្ធភាពអាចបង់ថ្លៃជួលតំណាង និងទីប្រឹក្សាខាងច្បាប់ ។ ការនេះអាចផ្តល់ជាមូលដ្ឋានសំរាប់អភិវឌ្ឍន៍គ្រោងការណ៍ជំនួយខាងច្បាប់ ដើម្បីផ្តល់សេវាច្បាប់ជាមូលដ្ឋាន ចំពោះអ្នកក្រីក្រ ក៏ដូចជាដើម្បីរិះរកបង្កើតជំនួយខាងច្បាប់ផ្តល់ថវិការដោយរដ្ឋ ដូចដែលបានបង្កើតនៅក្នុងប្រទេស ដ៏ទៃទៀត ។ ក្រុមការងារក្រៅផ្លូវការមួយបានបង្កើតហើយ ។ បច្ចុប្បន្ន គំរោងការណ៍នេះស្ថិតនៅក្នុងដំណាក់កាលជាបឋមនៅឡើយ ។

៣៣. ការិយាល័យក៏បានសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវី និងសាលាបណ្តុះបណ្តាលចៅក្រមនិងព្រះរាជអជ្ញាដែលទើបបង្កើតថ្មី ដើម្បីជួយធានាថាសិទ្ធិមនុស្សត្រូវបានបញ្ចូលដោយត្រឹមត្រូវទៅក្នុងកម្មវិធីនៃស្ថាប័នទាំងនេះ ដើម្បីរិះរកសេចក្តីត្រូវការធំទូលាយថែមទៀត និងដើម្បីឱ្យដឹងច្បាស់ថាតើការិយាល័យអាចជួយយ៉ាងដូចម្តេចឱ្យបានល្អប្រសើរ ។ ការិយាល័យបានផ្តល់ឯកសារដល់ស្ថាប័នទាំងពីរនេះ។

### (ii) ជំនួយដល់កិច្ចដំណើរការតាក់តែងច្បាប់: សេចក្តីព្រាង និងការអនុវត្តច្បាប់ ដើម្បីជំរុញ និងគោរពសិទ្ធិមនុស្ស

៣៤. ការិយាល័យបានបន្ត ឃ្លាំមើល និងផ្តល់យោបល់ ដល់សេចក្តីព្រាងច្បាប់ និងបទបញ្ជា ធ្វើយ៉ាងណាឱ្យមានការប្រព្រឹត្តតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងមានអគុណភាពបច្ចេកទេសល្អ ។ ការិយាល័យបានផ្តោតការយកចិត្តទុកដាក់ទៅលើសេចក្តីព្រាងច្បាប់ជំរើស មួយចំនួនដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអាណត្តិរបស់ខ្លួន និងជាអាទិភាពជាទូទៅ និងបានផ្តល់អត្ថាធិប្បាយ ក្នុងពេលធ្វើសេចក្តីព្រាង និងការពិភាក្សានៅសភា ។ ច្បាប់ដែលត្រូវបានយកចិត្តទុកដាក់ជាពិសេស រួមមានច្បាប់ទាក់ទិនទៅនឹងៈ អំពើហឹង្សាក្នុងគ្រួសារ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅ ក្រមឋានៈរបស់ចៅក្រមនិងព្រះរាជអាជ្ញា ច្បាប់ប្រឆាំងអំពើពុករលួយ ការបង្ក្រាបការជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ។ ការិយាល័យបានផ្តល់អត្ថាធិប្បាយលំអិតលើសេចក្តីព្រាងច្បាប់ស្តីពីឋានៈរបស់ចៅក្រមនិងព្រះរាជអាជ្ញា និងបានផ្តល់ជំនួយបន្ថែមក្នុងការបញ្ចប់សេចក្តីព្រាងច្បាប់នេះ ។ បុគ្គលិកបានបន្តតាមដានការជឿនលឿនទៅមុខក្នុងការរៀបចំក្រមព្រហ្មទ័ណ្ឌ និងក្រមនៃនីតិវិធីព្រហ្មទ័ណ្ឌ (ដែលត្រូវបានព្រាងដោយមានជំនួយពីអ្នកជំនាញការពីប្រទេសបារាំង) និងក្រមរដ្ឋប្បវេណី និងក្រមនៃនីតិវិធីរដ្ឋប្បវេណី (ដែលត្រូវបានព្រាងដោយមានជំនួយពីអ្នកជំនាញការមកពីប្រទេសជប៉ុន) ។ ការិយាល័យបានកត់សំគាល់អំពីសារសំខាន់នៃការធានាឱ្យមានភាពស្របគ្នារវាងក្រមទាំងនេះ ក៏ដូចជាជាមួយច្បាប់មានស្រាប់ ។ ការិយាល័យក៏បានគូសបញ្ជាក់អំពីសេចក្តីត្រូវការនៃច្បាប់ងាយយល់ និងអាចរកបាន ។

៣៥. ការិយាល័បានបន្តជំរុញធ្វើឱ្យមានការចូលរួមក្នុងកិច្ចដំណើរការតាក់តែងច្បាប់ ។ ការិយាល័យ បានលើកឡើងទាំងអំពីសេចក្តីត្រូវធ្វើការសាកសួរយោបល់ក្នុងកិច្ចដំណើរការធ្វើសេចក្តីព្រាងច្បាប់ និងការពិនិត្យពិច័យដោយសាធារណៈជនមុនការអនុម័តច្បាប់ ដែលការិយាល័យ និងលោកតំណាង ពិសេស តែងតែបានលើកឡើងជាបន្តបន្ទាប់ជាមួយរដ្ឋាភិបាល និងរដ្ឋសភា តែតែងតែត្រូវបានបំភ្លេច ។ នៅពេលថ្មីៗបំផុតនេះ សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី ។ សេចក្តីព្រាងចុងក្រោយ ត្រូវបានរៀបចំឡើង ដោយពុំបានសាកសួរយោបល់ដោយទូលំទូលាយ និងការពិភាក្សាជាសាធារណៈទេ ។

## ឆ. ការតព្វកិច្ចរាយការណ៍សិទ្ធិមនុស្ស និងការអនុវត្តអនុសាសន៍ ធ្វើឡើងដោយអង្គការឃ្លាំមើលសន្ធិសញ្ញា

៣៦. ប្រទេសកម្ពុជាជាភាគីមួយ នៃលិខិតុប្បករសិទ្ធិមនុស្សអន្តរជាតិចំនួន ៦[៣] ទោះបីជាប្រទេសនេះនៅមិនទាន់ទទួលនីតិវិធីនៃបណ្តឹងឯកជន តាមរយៈការចូលជាភាគីនៃពិធីសារជំរើសនៃកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងអនុសញ្ញាស្តីពីការលប់បំបាត់ការរើសអើងប្រឆាំងនារីភេទ ឬតាមរយៈសេចក្តីថ្លែងការណ៏ជំរើសស្របតាមមាត្រា ១៤ នៃអនុសញ្ញាស្តីពីការលប់បំបាត់ការរើសអើងពូជសាសន៍ និងមាត្រា ២២ នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងប្រព្រឹត្តកម្មឬការផ្តន្ទាទោសឃោរឃៅ អមនុស្សធម៌ និងធ្វើឱ្យថោកទាបដទៃទៀត ។ រដ្ឋាភិបាលបានប្រឈមមុខនឹងការពន្យារពេលដ៏យូរ ក្នុងការបំពេញ កាតព្វកិច្ចធ្វើរបាយការណ៏របស់ខ្លួន បានដាក់ជូនរបាយការណ៏លើកដំបូង ស្រមតាមកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ អនុសញ្ញាស្តីពីការលប់បំបាត់ការរើសអើងពូជសាសន៍ អនុសញ្ញាប្រឆាំង ទារុណកម្ម និងប្រព្រឹត្តកម្មឬការផ្តន្ទាទោសឃោរឃៅ អមនុស្សធម៌និងធ្វើឱ្យថោកទាបដទៃទៀត និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដោយយឺតពេលជាច្រើនឆ្នាំ ។ ប្រទេសនេះនៅមិនទាន់បានដាក់ជូនរបាយការណ៏ លើកដំបូងស្របតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ និងអនុសញ្ញាស្តីពីការលប់បំបាត់ការរើសអើង ប្រឆាំងនារីភេទ ។ ចាប់តាំងពីខែសីហា ឆ្នាំ ២០០១ មក ការទទួលខុសត្រូវនៃការធ្វើសេចក្តីព្រាងរបាយ ការណ៏ទាំងនេះ ត្រូវបានប្រគល់ទៅឱ្យគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ។ បច្ចុប្បន្ន សមាជិកគណៈកម្មាធិ ការធ្វើការលើរបាយការណ៏សន្និសញ្ញា បានចែកជាអនុគណៈកម្មាធិការពីរៈ មួយសំរាប់រៀបចំរបាយការណ៏ លើកដំបូងលើកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌ និងមួយទៀតរបាយការណ៏ តាមពេលកំណត់អំពីអនុសញ្ញាស្តីពីការលប់បំបាត់ការរើសអើងពូជសាសន៍ ។ លើសពីនេះទៅទៀត ក្រុម ប្រឹក្សាជាតិកម្ពុជាសំរាប់កុមារ បង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៥ ទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៏ស្តីពី អនុសញ្ញាស្តីពីសិទ្ធិកុមារ និងឃ្លាំមើលការអនុវត្តអនុសញ្ញានេះ ។ ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន ទទួល ខុសត្រូវក្នុងការធ្វើរបាយការណ៏អំពីអនុសញ្ញាស្តីពីការលប់បំបាត់ការរើសអើងប្រឆាំងនារីភេទ ។

---

[៣] ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នដល់អនុសញ្ញាស្តីពីការលប់បំបាត់គ្រប់រូបភាពនៃការរើសអើងពូជសាសន៍ ក្នុងឆ្នាំ ១៩៨៣ ។ ប្រទេសនេះបានចូលជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ អនុសញ្ញាស្តីពីការលប់បំបាត់គ្រប់រូបភាពនៃការរើសអើងប្រឆាំងនារីភេទ អនុសញ្ញាប្រឆាំងទារុណកម្ម និងប្រព្រឹត្តកម្មឬការផ្តន្ទាទោសឃោរឃៅ អមនុស្សធម៌ ឬធ្វើឱ្យថោកទាបដទៃទៀត និងអនុសញ្ញាស្តីពីសិទ្ធិកុមារ នៅក្នុងឆ្នាំ១៩៩២ ក្នុងរយៈកាលនៃអាជ្ញាធរអន្តរកាលរបស់អង្គការសហប្រជាជាតិនៅកម្ពុជា ។

៣៧. ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិនមនុស្សប្រចាំកម្ពុជា បានផ្តល់ជំនួយដល់ការរៀបចំរបាយការណ៍សន្ធិសញ្ញា ដល់រដ្ឋាភិបាល ចាប់តាំងពីឆ្នាំ ១៩៩៤ ហើយបានជួយក្នុងការរៀបចំរបាយការណ៍ដំបូងទាំងអស់ ។ ការិយាល័យបានបន្តជួយក្រុមប្រឹក្សាជាតិកម្ពុជាសំរាប់ស្ត្រី និងក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន ដើម្បីពិនិត្យឡើងវិញសេចក្តីព្រាងរបាយការណ៍លើកដំបូងរបស់ខ្លួន ស្របតាមអនុសញ្ញាស្តីពីការលុបបំបាត់គ្រប់រូបភាពនៃការរើសអើងប្រឆាំងនារីភេទ ។ សេចក្តីព្រាងរបាយការណ៍បញ្ចប់ ត្រូវបានដាក់ជូនគណៈរដ្ឋមន្ត្រីនៅក្នុងខែឧសភា ឆ្នាំ ២០០៣ ។ ការិយាល័យនឹងបន្តផ្តល់ជំនួយខ្លះសំរាប់របាយការណ៍ ស្តីពីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ និងអនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍ ដែលកំពុងរៀបចំនាពេលបច្ចុប្បន្ននេះ ទោះបីជាមិនមានកិរិតដូចកាលពីមុនក៏ដោយ ។

៣៨. ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ក៏បានរិះរកវិធីដែលអាចជួយបានកាន់តែល្អ ដល់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្នុងការពង្រឹងសមត្ថភាពបុគ្គលិក ដើម្បីរៀបចំរបាយការណ៍សន្ធិសញ្ញាជាទៀងទាត់ ។ បច្ចុប្បន្ន គណៈកម្មាធិការពុំបានទទួលថវិការទេ ហើយមិនបានប្រមូលឯកសារសព្វមុខនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ឬបញ្ហាសិទ្ធិមនុស្សក្នុងស្រុកទេ ។ ការិយាល័យនឹងបន្តផ្តល់ទីប្រឹក្សាខាងបច្ចេកទេស ជំនួយខាងការបកប្រែរបាយការណ៍ទៅជាភាសាអង់គ្លេស ដោយផ្តោតទៅការបើកវគ្គហ្វឹកហ្វឺន និងផ្តល់ឯកសារ និងធនធានជាសម្ភារៈ សំរាប់គណៈកម្មាធិការ ។

៣៩. ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធមនុស្សប្រចាំកម្ពុជា បានបន្តតាមដានសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការ អំពីការរើសអើងពូជសាសន៍ និងគណៈកម្មាធិការសិទ្ធមនុស្ស និងសេចក្តីសន្និដ្ឋាន និងអនុសាសន៍ជាបណ្តោះអាសន្ន កាលពីពេលថ្មីៗនេះ ដែលចេញផ្សាយដោយគណៈកម្មាធិការប្រឆាំងទារុណកម្ម នៅក្នុង សម័យប្រជុំលើកទី ៣០ របស់ខ្លួន នៅក្នុងខែឧសភា ឆ្នាំ ២០០៣ ។ របាយការណ៍ទី ១ របស់ប្រទេសកម្ពុជា លើអនុសញ្ញាប្រឆាំងទារុណកម្ម និងប្រព្រឹត្តកម្មនិងការផ្តន្ទាទោសឃោរឃៅអមនុស្សធម៌ និងធ្វើឱ្យថោក ទាបដទៃទៀត ដែលត្រូវបញ្ចប់នៅក្នុងខែវិច្ឆិកា ឆ្នាំ ១៩៩៣ និងបានដាក់ជូននៅក្នុងខែសីហា ឆ្នាំ ២០០២ ត្រូវ បានពិនិត្យដោយគណៈកម្មាធិការ នៅក្នុងខែមេសា ឆ្នាំ ២០០៣ ។ ជាអកុសល ពុំមានគណៈប្រតិភូមកពី ប្រទេសកម្ពុជា មានវត្តមាននៅក្នុងពេលគណៈកម្មាធិការពិនិត្យរបាយការណ៍នោះទេ ។ គណៈកម្មាធិការបាន

សុំឱ្យរដ្ឋាភិបាល ផ្តល់ចម្លើយទៅនឹងសំណួរលើកឡើងដោយសមាជិកគណៈកម្មាធិការដោយផ្ទាល់មាត់ និង ទៅនឹងបញ្ហាដែលបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានរបស់គណៈកម្មាធិការ និងអនុសាសន៍ជាបណ្តោះអាសន្ន ឱ្យបានមុនថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០៣ ។ ការិយាល័យបានបកប្រែសេចក្តីសន្និដ្ឋាននិងអនុសាសន៍ជាបណ្តោះ ជាភាសាខ្មែរ ហើយបានបញ្ជូនទៅឱ្យស្ថាប័នពាក់ព័ន្ធ ក្នុងនេះរួមមានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា នាយកនាយកដ្ឋានព័ន្ធនាគារ និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជ. កម្មវិធី ជំនួយផ្នែកការអប់រំ បច្ចេកទេស និងសេវាកម្មទីប្រឹក្សា

### (i) ជំនួយថវិកា និងបច្ចេកទេស ដល់អង្គការក្រៅរដ្ឋាភិបាល

៤០. ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តផ្តល់ការហ្វឹកហ្វឺន ជំនួយផ្នែកច្បាប់និងយោបល់ផ្នែកបច្ចេកទេសដទៃទៀត និងជំនួយខាងថវិកា ដើម្បីពង្រឹងសមត្ថភាពអង្គការក្រៅរដ្ឋាភិបាល កម្ពុជា និងអង្គការសង្គមស៊ីវិលដទៃទៀត ដើម្បីបំពេញសកម្មភាពរបស់ពួកគេ ក្នុងការជំរុញ និងការការពារ សិទ្ធិមនុស្ស ។

៤១. ការិយាល័យបានបញ្ចប់ការងាររបស់ខ្លួន ទាក់ទិនទៅនឹងជំនួយផ្តល់ឱ្យក្រោមគំរោងការណ៍សកម្មភាពសហគមន៍រួមគ្នា (ដែលជាគំរោងការណ៍រួមជាមួយយូអិនឌីភី) និងកម្មវិធីគាំទ្រអង្គការក្រៅរដ្ឋាភិបាល (ផ្តល់ថវិកាដោយមូលនិធិនៃការចូលរួមវិភាគទានដោយស្មគ្រចិត្ត សំរាប់ការអប់រំសិទ្ធិមនុស្សនៅកម្ពុជា) ។ បន្ទាប់ពីមូលនិធិត្រូវបានផ្តល់ឱ្យហើយ ការិយាល័យបានជួយដល់គំរោងការណ៍ធ្វើការវាយតម្លៃធ្វើឡើងដោយអ្នកទទួលជំនួយ និងបានបញ្ចប់របាយការណ៍ចុងក្រោយ ។ ការផ្តល់ជំនួយក្រោមគំរោងការណ៍សកម្មភាពសហគមន៍រួម ទាក់ទិនទៅនឹងការអប់រំ និងសកម្មភាពកសាងសមត្ថភាព លើបញ្ហាដូចជាសិទ្ធិកុមារ សិទ្ធិជនអន្តោប្រាម សិទ្ធិមនុស្សនិងប្រជាធិបតេយ្យ ការបោះឆ្នោត សិទ្ធិជនជាតិភាគតិច និងការចូលរួមក្នុងជីវភាពសាធារណៈ និងរដ្ឋាភិបាលមូលដ្ឋាន ។ គំរោងការណ៍នេះ ធ្វើឡើងដើម្បីឱ្យមានការយល់ថែមទៀតអំពីតម្លៃរបស់សិទ្ធិមនុស្ស និងប្រជាធិបតេយ្យនៅក្នុងតំបន់ដាច់ស្រយាល ហើយត្រូវបានអនុវត្តជាទូទៅដោយអង្គការធ្វើការនាកិរិតសហគមន៍ ។ ចំពោះការផ្តល់ថវិកាតាមកម្មវិធីគាំទ្រអង្គការក្រៅរដ្ឋាភិបាល គំរោងការណ៍

ដែលត្រូវបានផ្តល់មូលនិធិ មានរួមបញ្ចូលការគាំទ្រក្នុងវិស័យតំណាងខាងផ្លូវច្បាប់សំរាប់កុមារ សិទ្ធិជនជាតិភាគតិច ការអប់រំប្រឆាំងអំពើពុករលួយ និងក្មេងកំព្រាដោយ HIV/AIDS ។

៤២. មូលនិធិដែលនៅទទួលបានមកពីការរួមវិភាគទានរបស់ធនាគារពិភពលោក យូអិនអេហ្វភីអេ យូនីសែហ្វ អង្គការសុខភាពពិភពលោក និងយូអិនឌីភី សំរាប់ទិវាសិទ្ធិមនុស្សនៅក្នុងខេត្តបាត់ដំបង ត្រូវបានប្រើដើម្បីគាំទ្រគំរោងការណ៍តូចៗបួន ។ ទាំងនេះមាន HIV/AIDS និងការរើសអើង ការជំរុញបណ្តាញការងារ និងការគាំទ្រសហគមន៍នេសាទ កុមារនៅក្នុងពន្ធនាគារ និងការជំរុញសិទ្ធិមនុស្សតាមរយៈប្រពៃណី សិល្បៈ កំផ្លែង និងរបាំ ។

## (ii) ការអប់រំអប់ថ្នាក់ឧត្តមសិក្សា

៤៣. ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានរួមចំណែកដើម្បីអភិវឌ្ឍន៍មេរៀនសិទ្ធិមនុស្ស នៅមហាវិទ្យាល័យនីតិសាស្ត្រ និងសេដ្ឋកិច្ច នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ ការិយាល័យបានពិនិត្យមេរៀនឡើងវិញ ព្រមទាំងពិនិត្យកំណត់បង្រៀន ដើម្បីរកមើលការខ្វះខាតជាសក្តានុពល និងដើម្បីផ្តល់យោបល់ ដើម្បីកែលំអគុណភាព និងស្របតាមលក្ខណៈរបស់កម្ពុជា ។ ការិយាល័យក៏បានពិគ្រោះយោបល់ជាមួយ ស្ថាប័ន សិក្សាជាន់ខ្ពស់ដទៃទៀត និងជាមួយនិស្សិត ដើម្បីកែលំអការបង្រៀនសិទ្ធិមនុស្សឱ្យបានទូទៅ ជាងនេះ ។

## (iii) ការបកប្រែលិខិតុប្បករ សេចក្តីប្រកាស និងសេចក្តីណែនាំ ស្តីពីសិទ្ធិមនុស្ស

៤៤. ការបកប្រែជាភាសាខ្មែរបច្ចុប្បន្ន នៃសន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗ និងសេចក្តីប្រកសាជាសកលស្តីពីសិទ្ធិមនុស្ស មានភាពមិនត្រឹមត្រូវច្រើន ។ អាស្រ័យហេតុនេះ ការិយាល័យបានជួយបង្កើតក្រុមការងារមួយក្នុងឆ្នាំ ២០០២ ដើម្បីពិនិត្យការបកប្រែឡើងវិញ និង បង្កើតឡើងនូវការបកប្រែសន្ធិសញ្ញាទាំងឡាយឱ្យត្រឹមត្រូវតាមច្បាប់ និងងាយយល់ ។ ក្រុមការងារមានសមាសភាគជាបុគ្គលមកពីស្ថាប័នដ៏ទូលំទូលាយ រួមមានរដ្ឋសភា អង្គការក្រៅរដ្ឋាភិបាល ក្រសួងយុត្តិធម៌ក្រសួងអប់រំ រាជបណ្ឌិតសភាភ្នំពេញ គណៈកម្មការសិទ្ធិ មនុស្សនិងទទួលពាក្យបណ្តឹងរបស់ព្រឹទ្ធសភា និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ។

សន្ធានុក្រមសិទ្ធិ មនុស្ស (ខ្មែរ- អង់គ្លេស) មួយក៏កំពុងរៀបចំដែរ ។ ការពិនិត្យការបកប្រែឡើងវិញមានគំរោងបោះពុម្ពនៅក្នុងខែកញ្ញានេះ ។ ក្រុមការងារក៏បានពិនិត្យ និងកែឡើងវិញផងដែរសេចក្តីប្រកាសអន្តរជាតិនា នា ដែលបានបកប្រែដោយបុគ្គលិកការិយាល័យក្នុងនេះរួមមានសេចក្តីប្រកាសស្តីពីសិទ្ធិជនពិការ សេចក្តីប្រកាសស្តីពីសិទ្ធិរបស់មនុស្សជាសមាជិកអប្បភាគជនខាងជនជាតិឬជាតិពន្ធ សាសនា និងភាសា សេចក្តីប្រកាសស្តីពីសិទ្ធិនិងការទទួលខុសត្រូវរបស់បុគ្គល ក្រុមនិងអង្គការសង្គមធ្វើការដើម្បីជំរុញនិងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល និងគោលការណ៍អនុសាសន៍ និងការណែនាំស្តីពីការជួញដូរមនុស្ស ។

### (iv) ពតិមានសាធារណៈ និងការផ្តល់សេវាឱ្យទៅដល់គ្រប់ទិសទី

៤៥. ការបោះពុម្ពផ្សាយសិទ្ធិមនុស្ស ច្បាប់ និងឯកសារពតិមាន បានបន្តចែកជូនជាទៀងទាត់ជាសាធារណៈ ដល់សាធារណៈជនជាទូទៅ អង្គការក្រៅរដ្ឋាភិបាល និស្សិត និងមន្ត្រីរដ្ឋាភិបាល ។ របាយការណ៍ និងសេចក្តីថ្លែងការណ៏នានា របស់លោកតំណាងពិសេស របាយការណ៍សំខាន់ៗរបស់លោកអគ្គលេខាធិការ ដូចជារបាយការណ៏ទាក់ទិនទៅនឹងការវិនិច្ឆ័យទោសមេដឹកនាំថ្នាក់ខ្ពស់របស់ខ្មែរក្រហម ក៏ដូចជាសេចក្តីសំរេចចិត្តរបស់មាហាសន្និបាត និងរបស់គណៈកម្មការសិទ្ធិមនុស្ស ត្រូវបានបកប្រែជាភាសាខ្មែរ ជាទៀងទាត់ដើម្បីចែកផ្សាយ ។

៤៦. កិច្ចព្រមព្រៀងមួយរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការជំនុំជំរះក្តីក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចុះហត្ថលេខានៅក្នុងទីក្រុងភ្នំពេញ នៅថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០០៣ ។ នៅមានកិច្ចការច្រើនទៀតដែលត្រូវធ្វើ មុនឈានដល់ការបេង្កើតសាលាជំនុំជំរះក្តី ដើម្បីឱ្យការវិនិច្ឆ័យទោសនឹងធ្វើទៅបាន ។ ការិយាល័យយល់ឃើញថាការងាររបស់ខ្លួនមានសារសំខាន់ចំពោះអ្វីដែលទាក់ទងដល់ការអប់រំសាធារណៈ
ព្រមជាមួយលទ្ធភាពដែលការិយា ល័យ ត្រូវដើរតួនាទីក្នុងការឃ្លាំមើលការវិនិច្ឆ័យទោសនេះ ផងដែរ ។

## ឈ. កិច្ចសហប្រតិបត្តិការ និងការសំរបសំរួល ជាមួយប្រព័ន្ធអង្គការសហប្រជាជាតិ អ្នកផ្តល់ជំនួយ និងសហគមន៍ទូត

៤៧. ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ជាសមាជិកនៃក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស និងធ្វើការជាមួយទីភ្នាក់ងារដទៃទៀតលើបញ្ហាដែលយកចិត្តទុកដាក់ដូចគ្នា ដូចជាជាមួយយូណេស្កូចំពោះសិទ្ធិខាងការអប់រំ ជាមួយយូនីសែហ្វចំពោះតុលាការសំរាប់កុមារនិងការជួញដូរមនុស្ស និងជាមួយអង្គការលំនៅដ្ឋានរបស់អង្គការសហប្រជាជាតិចំពោះសិទ្ធិមានទីលំនៅ ។ ការិយាល័យបានផ្តល់ជូនសមាជិកក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ និងតួអង្គការពាក់ព័ន្ធដទៃទៀត នូវពត៌មានស្តីពីការបញ្ចូលបទដ្ឋានសិទ្ធិមនុស្សក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងទិសដៅអភិវឌ្ឍន៍សហសវត្ស ស្របទៅតាមសេចក្តីព្រាងសេចក្តីណែនាំរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ស្តីពីប្រធានបទនេះ ដែលបានអភិវឌ្ឍន៍ឡើងនៅក្នុងឆ្នាំ ២០០២ ។

៤៨. នៅឆ្នាំ ១៩៩៧ កម្មវិធីកែទម្រង់របស់លោកអគ្គលេខាធិការ បានសន្យាថានឹងបញ្ចូលសិទ្ធិមនុស្សផែនការ និងការអនុវត្តកម្មវិធី ទៅក្នុងការវិភាគក៏រិតប្រទេស ។ ក្នុងឆ្នាំ ២០០២ កម្មវិធីកែទម្រង់លើកទី ២ បានគូសបញ្ជាក់អំពីសេចក្តីត្រូវការរបស់ក្រុមប្រចាំប្រទេស - រួមមានមូលនិធិនិងកម្មវិធីរបស់អង្គការសហប្រជាជាតិ ទីភ្នាក់ងារជំនាញ និងធនាគារពិភពលោក - "ទទួលបានពត៌មាន ការវិភាគ និងឧទាហរណ៍អំពីថាតើត្រូវបញ្ចូលកម្មវិធីសិទ្ធិមនុស្សទៅក្នុងកម្មវិធីរបស់ប្រទេសយ៉ាងដូចម្តេច"?[៤] ។ នៅកម្ពុជា ក្រុមប្រចាំប្រទេស បានចាប់ ផ្តើមធ្វើការក្នុងទិសនេះ ហើយការិយាល័យបានអភិវឌ្ឍន៍សកម្មភាពដើម្បីគាំទ្រសមាជិកក្រុមប្រចាំប្រទេស ក្នុងកិច្ចខិតខំរបស់ពួកគេដើម្បីបញ្ចូលសិទ្ធិមនុស្សទៅក្នុងកម្មវិធីក្នុងប្រទេសរបស់ពួកគេ ។

៤៩. សព្វថ្ងៃ ការិយាល័យកំពុងរួមចំណែកក្នុងការពិនិត្យពាក់កណ្តាលអាណត្តិនៃក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ និងបានចាប់ផ្តើមចូលរួមសកម្មភាពរបស់គណៈកម្មាធិការទីប្រឹក្សាស្តីពីទិសដៅ

---

[៤] A/57/387 កថាខ័ណ្ឌ ៥១ ។

អភិវឌ្ឍន៍សហសវត្ស ដើម្បីជួយក្នុងការបញ្ចូលការដោះស្រាយបញ្ហាសិទ្ធិមនុស្ស ក្នុងការអភិវឌ្ឍន៍ក្នុងសកកម្មភាពរបស់ក្រុមប្រចាំប្រទេស ។

៥០. ការិយាល័យបានសហប្រតិបត្តិការជាមួយធនាគារពិភពលោក និងប្រទេសផ្តល់ជំនួយ និងទីភ្នាក់ងារអភិវឌ្ឍន៍ ក្នុងបញ្ហាជាច្រើនចំពោះការកែទម្រង់តុលាការនិងច្បាប់ ផ្នែកសង្គមកិច្ច និងការគ្រប់គ្រងធនធានធម្មជាតិក្នុងក្របខ័ណ្ឌការងាររបស់ក្រុមប្រឹក្សាយោបល់របស់ប្រទេសផ្តល់ជំនួយដល់ប្រទេសកម្ពុជា ។

៥១. ការិយាល័យបានផ្តល់ពត៌មានសង្ខេបជាទៀងទាត់ ដល់អ្នកការទូតដែលមកបំពេញទស្សនៈកិច្ចនិងប្រចាំក្នុងប្រទេស អង្គការអន្តរជាតិ និងបានរាយការណ៍ជាទៀងទាត់ជូនការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅទីក្រុងហ្សឺណែវ ។ ការិយាល័យបានផ្តល់របាយការណ៍ជូនដល់អ្នកសំរបសំរួលការស្នាក់នៅក្នុងប្រទេស និងប្រទេសផ្តល់ជំនួយ នៅពេលចាំបាច់ ។ ការិយាល័យបានធ្វើរបាយការណ៍លើប្រធានបទ និងឯកសារសង្ខេប បន្ថែមដើម្បីបំពេញសេចក្តីតម្រូវការខាងការធ្វើរបាយការណ៍របស់ប្រព័ន្ធអង្គការសហប្រជាជាតិ ។

## III. អំពីបុគ្គលិកការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា និងស្ថានភាពហិរញ្ញវត្ថុរបស់មូលនិធិនៃការរួមវិភាគទានដោយស្មគ្រចិត្ត សំរាប់កម្មវិធីអប់រំសិទ្ធិមនុស្ស នៅក្នុងប្រទេសកម្ពុជា

៥២. ការិយាល័បានអនុវត្តកម្មវិធីរបស់ខ្លួន តាមរយៈការិយាល័យធំនៅក្នុងទីក្រុងភ្នំពេញ ការិយាល័យភូមិភាគនៅខេត្តបាត់ដំបង ការិយាល័យសំរាប់ការបោះឆ្នោតនៅខេត្តកំពង់ចាម និងការិយាល័យតូចៗនៅក្នុងតុលាការភ្នំពេញ និងទីក្រុងព្រះសីហនុ ។ រចនាសម្ព័ន្ធគ្រប់គ្រង ចែកជាការិយាល័យនាយិកា អង្គភាពរដ្ឋបាល អង្គភាពជំនួយការច្បាប់ និងអប់រំ ហ្វឹកហ្វឺននិងពត៌មាន ។ នៅពេលសរសេររបាយការណ៍នេះ ការិយាល័យមានបុគ្គលិកខ្មែរ ៣២ នាក់ អន្តរជាតិ ៧នាក់ និងសមាជិកម្នាក់មកពីកម្មវិធីស្មគ្រចិត្តអង្គការសហប្រជាជាតិ ។ ទីប្រឹក្សា ៧ នាក់ត្រូវបានជ្រើសរើសសំរាប់កម្មវិធីឃ្លាំមើលការបោះឆ្នោត ។

៥៣. នាយកដ្ឋានការិយាល័យទទួលខុសត្រូវខាងនយោបាយ និងការគ្រប់គ្រង រួមទាំងការគាំទ្រការសំរបសំរួលដល់លោកតំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ចូលរួមជាមួយប្រព័ន្ធអង្គការសហប្រជាជាតិ ធ្វើការជាមួយទីភ្នាក់ងារនិងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និងទំនាក់ទំនងជាមួយប្រទេសផ្តល់ជំនួយខាងក្រៅ ។

៥៤. អង្គភាពរដ្ឋបាល ផ្តល់សេវាកម្មខាងបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ សំរាប់ការិយាល័យ និងសំរាប់សំរួលការដឹកជញ្ជូន និងភស្តុភា ។ អង្គភាពនេះទទួលខុសត្រូវខាងការចាត់ចែងខាងពត៌មានផងដែរ ។

៥៥. ក្រុមការពារ និងអភិវឌ្ឍន៍នយោបាយ ទទួលខុសត្រូវខាងដឹកនាំកម្មវិធីបោះឆ្នោត ស៊ើបអង្កេតលើបណ្តឹងស្តីពីការរំលោភសិទ្ធិមនុស្ស រៀបចំរបាយការណ៍ប្រធានបទ និងធ្វើការជាមួយអង្គភាពដទៃទៀតលើបញ្ហាទាក់ទិននឹងការគ្រប់គ្រងផ្នែកយុត្តិធម៌ និងនិទ័ណ្ឌភាព ។

៥៦. អង្គភាពជំនួយការច្បាប់ ទទួលខុសត្រូវក្នុងការជួយដល់កិច្ចដំណើរការនៃការកែទម្រង់តុលាការ គាំទ្រការកែទម្រង់រចនាសម្ព័ន្ធរបស់ស្ថាប័នគន្លឹះនានា ដើម្បីធានាឯករាជ្យភាពរបស់តុលាការ និងជួយតុលាការក្នុងការដោះស្រាយភាពទន់ខ្សោយក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ។ អង្គភាពក៏ធ្វើការជាមួយវិជ្ជាជីវៈច្បាប់ និងជួយដល់កិច្ចដំណើរការធ្វើច្បាប់ ដោយផ្តល់អត្ថាធិប្បាយលើសេចក្តីព្រាងច្បាប់ជំរើស ដើម្បីធានាថាច្បាប់ទាំងនោះស្របទៅនឹងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលប្រទេសកម្ពុជាជាភាគី ។

៥៧. ក្រុមអប់រំ ហ្វឹកហ្វឺននិងពត៌មាន ទទួលខុសត្រូវខាងការផ្តល់សេវាសាធារណៈដល់គ្រប់ទិសទី និងខាងការអប់រំ ហ្វឹកហ្វឺន និងជំរុញការអនុវត្តសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ ។ ក្រុមនេះធ្វើការជាមួយទីភ្នាក់ងាររដ្ឋាភិបាល និងរវាងទីភ្នាក់ងារនានារបស់រដ្ឋាភិបាលលើសិទ្ធិនៃការដោះស្រាយជាមូលដ្ឋានចំពោះការកាត់បន្ថយ ភាពក្រីក្រ និងការអភិវឌ្ឍន៍ ។ ក្រុមនេះក៏បន្តទទួលខុសត្រូវក្នុងការផ្តល់ជំនួយក្នុងកិច្ចដំណើរការធ្វើរបាយ ការណ៍សន្ធិសញ្ញាផងដែរ ។

៥៨.  ថវិកាទៀងទាត់របស់អង្គការសហប្រជាជាតិ  គ្របដណ្តប់ចំណាយប្រតិបត្តិការរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា រួមមានប្រាក់ខែបុគ្គលិកអាជីពអន្តរជាតិ ៧ នាក់ និងបុគ្គលិកខ្មែរ ១៦ នាក់ ។ មូលនិធិនៃការរួមវិភាគទានដោយស្មគ្រចិត្តសំរាប់កម្មវិធីអប់រំសិទ្ធិមនុស្សនៅកម្ពុជា គ្របដណ្តប់លើការចំណាយដទៃទៀតទាំងអស់ (រួមមាន ប្រាក់ខែបុគ្គលិកដែលមិនមែនគ្របដណ្តប់ដោយថវិការទៀងទាត់) ។ មូលនិធិនៃការរួមវិភាគទានដោយស្មគ្រចិត្ត គ្រប់គ្រងដោយការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស/ហ្សឺណែវ ។

ការបកប្រែសំរួលពីអត្ថបទដើមជាភាសាអង់គ្លេស